# បណ្ដាញកសិករ និងធម្មជាតិ

ចាប់តាំងពីឆ្នាំ១៩៩៨មក ក្នុងនោះកសិករភាគច្រើនជាអ្នកដាំដំណាំស្រូវបានរៀបចំដោយខ្លួនឯង ក្នុងការបង្កើតអោយមានបណ្ដាញនិងសមាគមន៍ភូមិ តាមរយៈការជួយគាំទ្រពីអង្គការ សេដាក CEDAC ។ បណ្ដាញនិងសមាគមន៍ភូមិទាំងអស់នេះ កំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើតអោយមានការជួយគ្នា ទៅវិញទៅមក សាមគ្គីភាព និងសហប្រតិបត្តិការរវាងអ្នកភូមិ ក៏ដូចជាការសំរបសំរួល ព្រមទាំងបង្កើតអោយមានសកម្មភាពប្រមូលផ្ដុំតាមមូលដ្ឋាននៅក្នុងការអភិវឌ្ឍន៍កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ការអនុវត្តអាជីវកម្មសហករណ៍ និង ការអភិវឌ្ឍន៍សហគមន៍ ។

សកម្មភាពជាចំបងរបស់សមាគមន៍គឺ ការពង្រីកសក្ដានុពលកសិកម្ម ការសន្សំប្រាក់ និង កំចីឥណទាននៅតាមសហគមន៍ ទីផ្សារក្រុម បណ្ដុះបណ្ដាលកសិករវ័យក្មេង កសាងសមត្ថភាពចំពោះក្រុមស្ត្រី គាំទ្រកសិករក្រីក្រ លើកកំពស់នូវការយល់ដឹងពីបញ្ហាដែលទាក់ទងនឹងការអភិរក្សធនធានធម្មជាតិតស៊ូមតិជាមួយអាជ្ញាធរតំបន់ ។ល។ សមាគមន៍កសិករ ក៏ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើតអោយមានឥទិពលលើគោលនយោបាយអភិវឌ្ឍតំបន់ និង តស៊ូមតិជាមួយនឹងអាជ្ញាធរតំបន់ដើម្បីអោយ អាជ្ញាធរតំបន់មានការទទួលខុសត្រូវខ្ពស់ចំពោះការអភិវឌ្ឍន៍សហគមន៍ និង ការគ្រប់គ្រងធនធានធម្មជាតិ ។

គិតមកត្រឹមខែមិថុនា ឆ្នាំ២០០៩នេះ មានសមាគមកសិករចំនួន ១១០៧សមាគម ក្នុងចំណោម ១១០៤ភូមិ ១១ខេត្តទូទាំងប្រទេសកម្ពុជា ដែលមានសមាជិកសរុបចំនួន ៤០២៩២នាក់ (ស្ត្រី ២៣៥៩១នាក់) ត្រូវបានបង្កើតឡើង តាមរយៈការជួយគាំទ្រពី អង្គការ សេដាក CEDAC និងបណ្ដាញនិងសមាគមន៍ភូមិ ។ ចំណែកតួលេខមានការកើនឡើជាលំដាប់តាំងពីឆ្នាំ ២០០៤មក ។ សមាគមន៍ បានសហការគ្នាជាមួយនឹងបណ្ដាញជាតិឯករាជរី សហព័ន្ធដែលមានឈោះថា "បណ្ដាញកសិករនិងធម្មជាតិ" ។

កិច្ចប្រជុំសន្និបាតលើកដំបូងរបស់បណ្ដាញត្រូវបានធ្វើឡើងនាខែធ្នូ ឆ្នាំ ២០០៣ក្នុងខេត្តសៀមរាបដែលមានអ្នកចូលរួមប្រមានជា១០០នាក់ ហើយកិច្ចប្រជុំសន្និបាតលើកទី២បានធ្វើឡើងនាខែធ្នូឆ្នាំ២០០៤ ក្នុងខេត្តកំពង់ចាមដែលមានអ្នកចូលរួមប្រមានជា៣០០នាក់ ។ កិច្ចប្រជុំសន្និបាត បានបោះឆ្នោតជ្រើសរើសសមាជិក ១៣នាក់ អោយក្លាយជាគណៈកម្មាធិការបណ្ដាញ ហើយតំណាង ៦០នាក់ទៀត អោយទៅជាសមាជិក

សន្និបាតពិសេស។ គណៈកម្មាធិការនិង សមាជិកសន្និបាតពិសេសត្រូវបានចាត់អោយអនុវត្តនូវភារ កិច្ចច្បាប់ តំណាងFNN ក្នុងការចុះជួបជាមួយសាធារណៈជន និងផ្តល់នូវការគាំទ្រក្នុងការ កសាងសមត្ថភាពដល់ សមាជិកសមាគមន៍។ នាខែធ្នូ ឆ្នាំ ២០០៥ កិច្ចប្រជុំសន្និបាតបានធ្វើឡើង ក្នុងខេតព្រៃវែង ដែលមានអ្នក ចូលរួមប្រមាណជា៩០០នាក់។ កិច្ចប្រជុំមហាសន្និបាតលើកទី៤បានធ្វើឡើងនាខែ ធ្នូ ឆ្នាំ ២០០៦ក្នុង ខេត្តតាកែវ ដែលមានអ្នកចូលរួមមកពីតំណាង VFA ប្រមាណជា១៤០០នាក់។ កិច្ចប្រជុំមហាសន្និបាត លើក ទី៥បានធ្វើឡើងនាខែ មិនា ឆ្នាំ ២០០៨ ដែលបានបោះឆ្នោតជ្រើសរើសនូវគណៈកម្មាធិការបណ្តាញសំរាប់ អណត្តិទី៣ ហើយផែនការយុទ្ធសាស្រ្តសំរាប់រយះពេលវែងក៏បានធ្វើ ឡើងនៅពេលនោះដែរ។ កិច្ចប្រជុំមហា សន្និបាតលើកទី៦ បានធ្វើឡើងនាខែធ្នូឆ្នាំ២០០៨ ដែលមានអ្នកចូលរួមប្រមាណជា៦០នាក់ ហើយមាន គោលបំណងដើម្បីបង្ហាញនូវរចនាសម្ព័ន្ធថ្មីនៃ FNN ក្នុងឆ្នាំ២០០៨ ព្រមទាំងរៀបចំរចនាសម្ព័ន្ធនិង បោះឆ្នោត ជ្រើសរើសនូវ សមាជិកនៃក្រុមប្រឹក្សាភិបាល FNN និងរៀបចំផែនការ យុទ្ធសាស្រ្ត សំរាប់ រយះពេលវែង។

ក្រៅពីនេះ សេដាក ក៏មានដៃគូជាច្រើនទៀត ដែលគាំទ្រ FNN ផងដែរ។ ដៃគូទាំងនោះរួមមានៈមូលនិធិ អភិវឌ្ឍន៍អាឡឺម៉ង់ FNS (Friedrich Naumann Foundation, Germany), Agri-Terra (Netherlands) កសិកម្មវិទូបារាំង ដើម្បីការអភិវឌ្ឍន៍អន្តរជាតិ AFDI (French Agriculturist for International Development) គណៈកម្មាធិការបារាំង ដើម្បីការបង្រួបបង្រួមអន្តរជាតិ CFSI (French Committee for International Solidarity), ជំនួយការដើម្បីការអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណឺម៉ាក DANIDA (Danish International Development Assistance), Oxfam GB and Oxfam America ។ ឆ្នាំ ២០០៩ Agri-Terra បានផល់នូវជំនួយយ៉ាងធំដល់ FNN ។ខែមិនា ឆ្នាំ ២០០៦ FNN ត្រូវបានចុះបញ្ជីជាផ្លូវការជា "សមាគម កសិករជាតិ"។ FNN ក៏បានក្លាយជាសមាជិកអចិន្ត្រៃយ៍ នៃសមាគមន៍កសិករអាស៊ីសំរាប់ការអភិវឌ្ឍន៍ជនបទ ប្រកបដោយនិរន្តរភាព AFA (Asian Farmers' Association for Sustainable Rural Development) និង LVC (La Via Campensina) ផងដែរ។ **ដោយលោក ណយ គីមហុង**